សួស្តី នៅក្នុងរូបភាពនេះគឺនិយាយអំពីការទៅដកលុយនៅទូអេធីអឹម។ ដែលរូបភាពទី ១
យើងឃើញមានស្រ្តីម្នាក់ គាត់មានអាយុប្រហែលជា ២៥ ឆ្នាំ
គាត់ស្លៀកពាក់ឯកសណ្ឋានដូចជាអ្នកធ្វើការ។ ដោយគាត់មានពាក់អាវពណ៌ខៀវ ដៃវែង
ជាមួយនឹងសំពត់ត្រឹមជង្គង់ពណ៌ស គាត់មានស្ពាយកាបូបនៅចំហៀង ខាងស្តាំដៃរបស់គាត់
ដោយកាបូបគាត់គឺមានពណ៌ស។ នៅពេលដែលគាត់កំពុងតែរៀបចេញទៅខាងក្រៅ
គាត់ក៏បានដកកាបូបលុយចេញពីកាបូបរបស់គាត់ ដើម្បី
ដើម្បីមើលថាតើមានលុយនៅក្នុងកាបូបលុយនោះគ្រប់គ្រាន់ដែរឬទេ ពេលខ្លះគឺ
ពេលខ្លះគឺគាត់មិនបានដាក់លុយច្រើនក្នុងកាបូបលុយទេ។
អញ្ចឹងនៅពេលដែលគាត់ត្រូវការប្រើប្រាស់ គាត់អាច នៅពេលដែលគាត់ត្រូវការប្រើប្រាស់លុយ គាត់
គាត់ត្រូវពិនិត្យមើលលុយជាមុនសិន ឬក៏គាត់ត្រូវការបន្ថែមលុយចូលទៅក្នុងកាបូបលុយរបស់គាត់។
នៅពេលដែលគាត់កំពុងតែឆែកលុយនៅក្នុងកាបូបរបស់គាត់ យើងឃើញលុយនៅក្នុងកាបូប
កាបូបរបស់គាត់នៅសល់តែ ១០ ដុល្លារ ដូច្នេះគឺអត់គ្រប់គ្រាន់សម្រាប់គាត់ចាយ
ឬក៏ទិញអីវ៉ាន់ថ្ងៃនេះ។

បន្ទាប់មក រូបភាពទី ២ រូបភាពទី ២ រូបភាពទី ២
ក្រោយពេលដែលគាត់ឆែកកាបូបលុយគាត់ដែលគាត់ដាក់កាបូបនោះ
នៅក្នុងកាបូបស្ពាយចំហៀងរបស់គាត់ អញ្ចឹងក្រោយពេលដែលគាត់ឆែកលុយហើយ
គាត់ឃើញមានលុយតែ ១០ ដុល្លារនៅក្នុងកាបូបនោះ
បន្ទាប់មកគាត់ក៏ដាក់កាបូបនោះចូលទៅក្នុងកាបូបស្ពាយចំហៀងវិញ
ដោយគាត់ស្ពាយកាបូបនោះយ៉ាងជាប់ និងដៃខាងស្តាំរបស់គាត់ដាក់នៅលើកាបូបនោះ
ពីព្រោះដោយសារតែនៅពេលដែលយើងស្ពាយ និងដើរនៅតាមផ្លូវ គឺវារអិល ងាយស្រួលធ្លាក់ចុះ និង
និងពេលខ្លះអាចមានចោរ និង និងពេលខ្លះអាចមានចោរ
អញ្ចឹងនៅពេលដែលយើងដើរតាមផ្លូវយើងត្រូវតែមានការប្រុងប្រយ័ត្ន
កុំឲ្យចោរអាចលួចកាបូបរបស់យើងបាន។ អញ្ចឹងយើងឃើញស្រ្តីម្នាក់នោះ
ក្រោយពេលដែលគាត់ពិនិត្យមើលលុយនៅក្នុងកាបូបលុយរបស់គាត់ហើយ គាត់
ក្រោយពេលពិនិត្យលុយនៅក្នុងកាបូបលុយរបស់គាត់ហើយ
ដោយសារតែលុយនៅក្នុងកាបូបលុយមានតែ ១០ ដុល្លារ ដូច្នេះគាត់ត្រូវដើរមករកធនាគារ
ដើម្បីបើក ដើម្បីដកលុយពីទូអេធីអឹមបន្ថែម ដោយសារតែមានតែ ១០ ដុល្លារ គាត់មិនអាច
គាត់មិនអាចទិញអីវ៉ាន់ ឬក៏គាត់មិនអាចចាយសម្រាប់ថ្ងៃនេះបានទេ។
គាត់មិនអាចចាយគ្រប់គ្រាន់សម្រាប់ថ្ងៃនេះទេ។ អញ្ចឹងគាត់ត្រូវដើរទៅធនាគារដើម្បី
ដើម្បីរកទូអេធីអឹម ដើម្បីបើកលុយ ដើម្បីដកលុយ។ បន្ទាប់មកគាត់ដើរនៅតាមផ្លូវ ក៏បានទៅដល់

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ក៏បានទៅដល់ធនាគារ ក៏បានទៅដល់ធនាគារ ដោយយើងឃើញទ្វារធនាគារ គឺបិទជិត និងជាទ្វារកញ្ចក់។

រូបភាពទី ៣ ក្រោយពេលគាត់ដើរទៅដល់ធនាគារ គាត់ក៏បាន គាត់ក៏បានដើរចូល គាត់ក៏បានដើរ គាត់ក៏បានដើរចូលទៅខាងក្នុង។ បន្ទាប់មកគាត់ឃើញមានមនុស្សជាច្រើនកំពុងតែឈររង់ចាំ កំពុងតែឈររង់ចាំដកលុយចេញពីទូអេធីអឹម។ យើងឃើញមនុស្សឈរចាំជាជួរ ដោយយើងឃើញអ្នកទី ១ យើងឃើញមានបុរសម្នាក់ យើងឃើញគាត់ពាក់អាវស ដៃខ្លី ជាមួយនឹងខោសជើងវែង និងអ្នកទី ២ យើងឃើញ យើងឃើញបុរសម្នាក់ដែលគាត់ពាក់អាវ អាវ អាវយឺត យើងឃើញពាក់អាវយឺត ដៃខ្លី ពណ៌ពងមាន់ ជាមួយនឹងខោជើងវែងពណ៌ស និងមានកូនស្រី និងមានកូនស្រីម្នាក់នៅឈរជិតគាត់ ដោយយើងឃើញកូនស្រីរបស់គាត់គឺពាក់អាវដៃវែងពណ៌ស ជាមួយនឹងខោខ្មៅ។ អញ្ចឹងកូនស្រីរបស់គាត់មកជា កូនស្រីរបស់គាត់មក មកធនាគារជាមួយគាត់ដើម្បីមកបើក ដើម្បីមកដកលុយតាមទូអេធីអឹម។ ដោយសារតែមានមនុស្សច្រើន អញ្ចឹងពួកគាត់ត្រូវឈរតម្រង់ជួរ។ អញ្ចឹងគាត់ត្រូវ យើងឃើញគាត់កាន់ យើងឃើញគាត់ដាក់ដៃ កាន់កូនគាត់យ៉ាងជាប់ ពីព្រោះខ្លាចកូនគាត់រត់លេង ឬក៏រត់ទៅ ចេញទៅខាងក្រៅ អាច អាចនឹងមានគ្រោះថ្នាក់ ដោយសារតែក្មេងគឺរពឹស គឺមិន មិនចូលចិត្តឈរនៅតែមួយកន្លែងទេ អញ្ចឹងនៅពេលដែលគាត់កំពុងតែឈររង់ចាំនោះ គាត់កាន់កូនគាត់យ៉ាងជាប់មិនឲ្យរបូតដៃទេ។ បន្ទាប់មកយើងឃើញបុរសដែលឈរនៅខាងក្រោយ យើងឃើញគាត់ពាក់អាវយឺតដែរ ប៉ុន្តែមានអាវយឺត ប៉ុន្តែគាត់ពាក់អាវយឺតពណ៌ស្វាយ ខោសជើងវែង និងគាត់ឈរដៃ និងគាត់ឈរដាក់ដៃខាងស្តាំរបស់គាត់ចូលទៅក្នុងហោប៉ៅរបស់គាត់ អញ្ចឹងពួកគាត់ទាំងអស់គ្នាកំពុងតែឈរ កំពុងតែឈររង់ចាំដើម្បីអាចដកលុយ ដើម្បីអាចដកលុយចេញពីទូអេធីអឹម អញ្ចឹងពួកគាត់ម្នាក់ៗឈរតម្រង់ជួរ ដោយសារតែមានមនុស្សច្រើនពេក។ បន្ទាប់មកស្ត្រីដែលគាត់មានស្ពាយកាបូបពណ៌សនៅចំហៀងខាងស្តាំ ដោយគាត់ដាក់ដៃខាងស្តាំរបស់គាត់កាន់កាបូបនោះយ៉ាងជាប់ ក្រោយពេលដែលគាត់ដើរចូលមកក្នុងធនាគារ ដោយសារតែឃើញមានមនុស្សឈរជាច្រើន ដូច្នេះគាត់ក៏បានដើរទៅ ដើម្បីឈរតម្រង់ជួរនៅខាងក្រោយដើម្បីរង់ចាំដល់វេនរបស់គាត់។ ប្រសិនមិនឈរតម្រង់ជួរទេ នៅពេលដែលអ្នកក្រោយៗមកបន្តទៀត អ្នកក្រោយៗនឹងឈរតម្រង់ជួរ ដូច្នេះយើងនឹងអាចឈររង់ចាំយូរ។ ដូច្នេះប្រសិនបើទោះ ដូច្នេះបើទោះបីមានមនុស្សច្រើនយ៉ាងណាក៏ដោយ យើងត្រូវឈរតម្រង់ជួរ ដើម្បីឲ្យឆាប់បានដល់វេនរបស់ខ្លួន។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

រូបភាពទី ៤ រូបភាពទី ៤ ដោយសារតែមានមនុស្សច្រើនពេក យើងឃើញគាត់ឈររង់ចាំ
គាត់ឈររង់ចាំដោយមានអារម្មណ៍ថាធុញ គាត់មានអារម្មណ៍ថាធុញក្នុងការរង់ចាំ
ដោយសារតែនៅសល់មនុស្សច្រើនពេក។
យើងឃើញមនុស្សដែលនៅឈរខាងមុខគាត់នៅសល់ចំនួន ៣ នាក់ទៀត។
និងបុរសដែលពាក់អាវពណ៌សដៃខ្លី ខោជើងវែងកំពុងតែចាប់ផ្ដើម កំពុងតែចាប់ផ្ដើមដាក់កាត
កំពុងតែចាប់ផ្ដើមដាក់កាតអេធីអឹមរបស់គាត់ចូលទៅក្នុងទូអេធីអឹមនោះ
ដើម្បីអាចដកទឹកប្រាក់បាន។ អញ្ចឹងបន្ទាប់មកនឹងដល់វេនរបស់បុរសដែលគាត់មានកូន
បុរសដែលគាត់មានកូនស្រីមកជាមួយ បន្ទាប់ទៀត នឹងដល់វេនបុរសដែលគាត់ពាក់អាវយឺតពណ៌
ពណ៌ស្វាយ និងដាក់ដៃខាងស្ដាំចូលទៅក្នុងហោប៉ៅរបស់គាត់។ អញ្ចឹងស្ត្រីម្នាក់នោះគាត់ត្រូវ
គាត់ត្រូវឈររង់ចាំចំនួន គាត់ត្រូវឈររង់ចាំមនុស្សចំនួន ៣ នាក់ទៀត ទើបដល់វេនរបស់គាត់។

បន្ទាប់មកទៀត រូបភាពទី ៥ រូបភាពទី ៥ នៅពេលដែល នៅពេលដែល នៅពេលដែលអ្នកនៅខាង
នៅពេលដែលអ្នកនៅខាងមុខគាត់ ឬក៏នៅពេលដែលមនុស្សដែលឈរនៅខាងមុខគាត់ បាន
បានចូលទៅ បានចូលទៅដកលុយម្នាក់ម្ដងៗ ម្នាក់ម្ដងៗអស់ហើយ
ដូច្នេះយើងឃើញពេលនេះគឺដល់វេនរបស់គាត់។ យើងឃើញបុរសដែលពាក់អាវយឺតពណ៌ស្វាយ
ពាក់ខោពណ៌សជើងវែង ដាក់ដៃចូលទៅក្នុងហោប៉ៅរបស់គាត់
ក្រោយពេលដែលគាត់បានដកលុយហើយ គាត់ក៏បានដើរចេញ បន្ទាប់មកក៏ដល់វេនស្ត្រីម្នាក់នោះ
គាត់ក៏បានចូល ដើម្បីស៊កកាតអេធីអឹមរបស់គាត់ចូលទៅក្នុងទូអេធីអឹម ដើម្បីអាចដកលុយបាន
ក្រោយពេលដែលគាត់ឈររង់ចាំយ៉ាងយូរ។ ដោយមានមនុស្សច្រើន
ដោយមានមនុស្សច្រើនឈររង់ចាំ អញ្ចឹងនៅពេលនេះ គឺដល់វេនគាត់
គាត់អាចចូលទៅដកលុយនៅក្នុងទូអេធីអឹម គាត់អាចចូលទៅដកលុយតាមទូអេធីអឹមនោះបាន។

រូបភាពទីប្រាំ រូបភាពទី ៦ នៅពេលដែលគាត់ដើរមកដល់ទូអេធីអឹម គាត់ក៏បានយកកាត
យកកាតអេធីអឹមរបស់គាត់ដាក់ចូលទៅក្នុងទូអេធីអឹមនោះ។ ប្រសិនបើអត់មានកាតអេធីអឹម
នោះទេ យើងមិនអាចដកលុយចេញពីទូអេធីអឹមនោះបានឡើយ។ អញ្ចឹងគាត់ត្រូវ
នៅពេលដែលគាត់ចង់ដកលុយតាមអេធីអឹម តាមទូអេធីអឹម គាត់ត្រូវមានកាតមកជាមួយនឹង
គាត់មាន គាត់ត្រូវមានកាតយកមកជាមួយ ដើម្បីស៊កចូលទៅក្នុងទូនោះ។
អញ្ចឹងយើងឃើញស្ត្រីម្នាក់នោះ គាត់បានដកកាត ដកកាតរបស់គាត់
ចេញពីកាបូបស្ពាយចំហៀងរបស់គាត់។ បន្ទាប់មកគាត់ក៏បានស៊កចូលទៅក្នុងទូអេធីអឹមនោះ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មករូបភាពទី ៧ ក្រោយពេលដែលគាត់ស៊កកាតនោះ ចូលទៅក្នុងទូអេធីអឹមហើយ គាត់ក៏បានចុចលេខកូដសម្ងាត់ ពីព្រោះ ពីព្រោះលេខកូដសម្ងាត់ប្រើសម្រាប់ ការពារកុំឲ្យមាននរណាម្នាក់អាចលួច អាចលួចលុយ នៅក្នុង នៅក្នុងគណនីរបស់គាត់បាន។ ប្រសិនបើយើង ប្រសិនបើយើងអត់មានលេខសម្ងាត់នោះទេ យើងមិនអាចដកលុយចេញពីទូអេធីអឹមនោះបានឡើយ និងប្រសិនបើយើង ប្រសិន ប្រសិនបើ ប្រសិនបើមាននរណាម្នាក់ដឹងលេខសម្ងាត់យើង និងមាននរណាម្នាក់គាត់រើសបានកាតអេធីអឹមរបស់យើង និងដឹងលេខសម្ងាត់របស់យើង អញ្ចឹងអ្នកដែលរើសបាននោះ គាត់អាច គាត់អាចប្រើប្រាស់ និងអាចដកលុយចេញពីគណនីរបស់យើងបាន។ អញ្ចឹងនៅពេលដែលយើងមានកាតអេធីអឹម យើងត្រូវមានលេខកូដសម្ងាត់ ដើម្បីប្រើសម្រាប់ ប្រើសម្រាប់អាចដកលុយបាន។ អញ្ចឹងនៅពេលដែលយើងស៊កកាតចូលទៅក្នុងម៉ាស៊ីន យើងត្រូវវាយ វាយលេខកូដសម្ងាត់ចំនួន ៤ ខ្ទង់នោះចូលទៅក្នុងម៉ាស៊ីន។ អញ្ចឹងស្ត្រីម្នាក់នោះគាត់ចាប់ផ្ដើមវាយលេខកូដសម្ងាត់ លេខកូដសម្ងាត់ចូលទៅក្នុងម៉ាស៊ីននោះ ដើម្បីអាចដកទឹកលុយបាន។ បន្ទាប់មកទៀតគឺគាត់ចង់ យើងឃើញ អញ្ចឹងក្រោយពេលដែលគាត់បានវាយលេខកូដចូលទៅក្នុង បានវាយ បានវាយលេខកូដឬក៏លេខសម្ងាត់ចូលទៅក្នុងទូអេធីអឹមនោះរួចរាល់ហើយ គាត់ក៏បានវាយចំនួនទឹកលុយដែលគាត់ត្រូវការ ដកចេញ ដកចេញពីទូអេធីអឹមនោះ។ អញ្ចឹងគាត់វាយចំនួនទឹកលុយ ចំនួន ១៥០០ ដុល្លារ ប្រហែលជាគាត់ត្រូវការសម្រាប់បង់ថ្លៃ បង់ថ្លៃអ្វីមួយ ឬក៏សម្រាប់ទិញអ្វីមួយ អញ្ចឹងគាត់ដកលុយពី ពីទូអេធីអឹមនោះចំនួន ១៥០០ ដុល្លារ។ បន្ទាប់មកក្រោយពេលដែលគាត់វាយចំនួនទឹកលុយនោះរួចរាល់ហើយ យើងឃើញនៅលើ នៅលើ អេក្រង់របស់ របស់ទូម៉ាស៊ីនអេធីអឹមនោះ យើងឃើញមានអក្សរ yes ឬក៏ cancel។ yes មានន័យថាយើង យើង នៅពេលដែលយើងចុច yes បានន័យថាយើង យើងនឹងទទួលបានលុយ ១៥០០ ដុល្លារនោះ ប៉ុន្តែប្រសិនបើយើងចុច cancel មានន័យថាយើងលុបចោល មានន័យថាយើង អត់ចង់ យើងអត់ចង់ដកលុយ ១៥០០ ដុល្លារនោះទេ ប្រហែលជាយើងចង់ ចង់ដកចំនួនផ្សេងវិញ។ អញ្ចឹងយើងឃើញគាត់ ក្រោយពេលដែលគាត់វាយចំនួនទឹកលុយ ១៥០០ ដុល្លារហើយ នៅលើអេក្រង់ គឺចេញ គឺចេញអក្សរ yes និង cancel ដើម្បីសួរគាត់ថាតើគាត់ តើគាត់នឹង តើគាត់យល់ព្រម តើគាត់សម្រេចចិត្តដកលុយ ១៥០០ ដុល្លារហ្នឹង ឬក៏គាត់ចង់ គាត់ចង់លុបចោលវិញ។

បន្ទាប់មក រូបភាពទី ៨ រូបភាពទី ៨ ក្រោយពេលដែលគាត់វាយចំនួនទឹកលុយ ១៥០០ ដុល្លាររួចរាល់ហើយ គាត់ក៏បានចុចប៊ូតុងដែលមានអក្សរ yes នៅខាងលើ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងដើម្បីអាចទទួលបានទឹកលុយ ១៥០០ ដុល្លារនោះយកមកប្រើប្រាស់។
ក្រោយពេលដែលគាត់ចុចប៊ូតុង yes រួចរាល់ហើយ យើងឃើញរូបភាពទី ១០។

រូបភាពទី ១០ គឺគាត់កំពុងតែឈរ កំពុងតែឈររង់ចាំ
កំពុងតែឈររង់ចាំឲ្យម៉ាស៊ីនអេធីអឹមនោះដំណើរការ ដើម្បីអាចដកលុយចេញពី ចេញ
ដើម្បីអាចដកលុយបាន។ យើងឃើញ យើងឃើញទូអេធីអឹមនោះកំពុងដំណើរការ
និងយើងឃើញកន្លែងដែលលុយ និងយើងឃើញកន្លែងដែលយើងអាចដកលុយនោះ
មិនទាន់មានលុយលោតចេញមកខាងក្រៅទេ។ ដោយសារតែទូនោះ កំពុងដំណើរការ។
អញ្ចឹងស្ត្រីម្នាក់នោះគាត់ត្រូវឈរ គាត់ត្រូវឈររង់ចាំសិន គាត់ត្រូវឈររង់ចាំមួយសន្ទុះសិន។

ក្រោយពេលដែលគាត់ឈររង់ចាំមួយសន្ទុះហើយ យើងឃើញរូបភាពទី ១១ យើងឃើញរូបភាពទី
១១ កាតអេធីអឹមរបស់គាត់ក៏បានលោតចេញមកខាងក្រៅវិញ។ អញ្ចឹងកាតអេធីអឹម
ពេលខ្លះប្រសិនបើយើងវាយលេខកូដខុស ឬក៏យើង នៅពេលខ្លះគឺយើងអត់ចេះប្រើម៉ាស៊ីននោះ
កាតនោះនឹងអាចជាប់នៅក្នុងម៉ាស៊ីនអេធីអឹមនោះ និងយើង
នៅពេលដែលកាតនោះជាប់នៅក្នុងទូអេធីអឹម យើងត្រូវ យើងត្រូវតែទៅកាន់ភ្នាក់ងារ
តែទៅកាន់ធនាគារដែលគាត់អាចជួយ អាចជួយដកកាតនោះចេញពី ចេញពីទូអេធីអឹមនោះ
អញ្ចឹងមានន័យថា នៅពេលដែលយើងប្រើកាតអេធីអឹមយើងត្រូវមានការប្រុងប្រយ័ត្ន
ពីព្រោះពេលខ្លះកាតនោះនឹងអាច ពេលខ្លះម៉ាស៊ីននោះមិនអាច ពេលខ្លះម៉ាស៊ីន
ពេលខ្លះកាតនោះមិន នៅពេលដែលយើងដាក់ចូលទៅក្នុងម៉ាស៊ីន
និងនៅពេលដែលយើងវាយលេខកូដ ឬក៏លេខសម្ងាត់ខុស
និងពេលខ្លះនៅពេលដែលមានបញ្ហាអ្វីមួយ កាតនោះមិនបានចេញមកខាងក្រៅទេ មិនបាន
មិនបានចេញមកខាងក្រៅទេ ដោយសារតែមានបញ្ហាម៉ាស៊ីននោះ។ អញ្ចឹងប្រសិនបើយើងមានបញ្ហា
យើងអាច យើងអាចតែទៅកាន់ អ្នក អ្នកធ្វើការនៅ បុគ្គលិកធ្វើការនៅធនាគារ អញ្ចឹងពួកគាត់នឹងមក
មក ពួកគាត់នឹងមកយកកាតចេញពីទូអេធីអឹមនោះ។

បន្ទាប់មករូបភាពទី ១២ រូបភាពទី ១២ ក្រោយពេលដែលកាតនោះ
នៅពេលដែលកាតនោះចេញមកខាងក្រៅ ស្ត្រីម្នាក់នោះគាត់ក៏បានដកកាត់នោះ
គាត់ក៏បានដកនិងយកកាតនោះ ដើម្បីដាក់ត្រលប់ចូលទៅក្នុងកាបូបរបស់គាត់វិញ។ អញ្ចឹង
គាត់ត្រូវរក្សាកាតនោះ គាត់ត្រូវរក្សាកាតនោះ ដោយរក្សាទុកនៅក្នុង ក្នុង
ដោយរក្សាទុកនៅក្នុងកាបូបរបស់គាត់ អញ្ចឹងក្រោយពេលដែលទូអេធីអឹម
ក្រោយពេលដែលទូអេធីអឹម ក្រោយពេលដែលទូអេធីអឹមកំពុងតែដំណើរការ កំពុងតែដំណើរការ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដើម្បីអាចដកលុយបាន នៅពេលដែលទូអេធីអឹមនោះដំណើរការរួចរាល់ហើយ
កាតក៏បានចេញមកខាងក្រៅ អញ្ចឹងគាត់អាចយកកាតនោះ ចេញពីទូអេធីអឹមនោះបាន។

បន្ទាប់មកទៀតរូបភាពទី ១៣ រូបភាពទី ១៣ យើងឃើញលុយក៏បានចេញមកខាងក្រៅផងដែរ
អញ្ចឹងទឹកលុយចំនួន ១៥០០ ដុល្លារ ដែលគាត់បានដកចេញពី ដកចេញពីទូអេធីអឹមនោះ
គាត់ក៏បានដកចេញមក លុយនោះក៏បានចេញមកខាងក្រៅតាមម៉ាស៊ីនអេធីអឹមនោះ។

បន្ទាប់មករូបភាពទី ១៤ រូបភាពទី ១៤ គាត់ក៏បាន គាត់ក៏បានយកលុយចេញពីទូអេធីអឹមនោះ។
ដូច្នេះការប្រើប្រាស់អេធីអឹមគឺងាយស្រួល
យើងមិនចាំបាច់ដាក់លុយច្រើននៅក្នុងកាបូបរបស់យើងទេ
ពីព្រោះនៅពេលខ្លះប្រសិនបើយើងដាក់លុយច្រើននៅក្នុងកាបូបរបស់យើង
ពេលខ្លះប្រសិនបើមានចោរឆក់ ឬក៏ចោរលួច យើងអាច យើងអាច យើងអាចនឹងបាត់បង់លុយនោះ
ប៉ុន្តែប្រសិនបើយើងគ្រាន់តែមានកាតអេធីអឹមនៅក្នុងកាបូបរបស់យើង យើងអាចដកលុយ
យើងអាចដកលុយ ឬក៏ដកប្រាក់នៅពេលណាក៏បានដែរ ពីព្រោះ ពីព្រោះទូអេធីអឹមគឺ ២៤ ម៉ោង
អញ្ចឹងយើងអាចដកគ្រប់ពេល ឬក៏ យើងអាចដកគ្រប់ពេល គ្រប់ពេលវេលា
ឬក៏គ្រប់ពេលដែលយើងត្រូវការប្រាក់ ឬគ្រប់ពេលដែលយើងត្រូវប្រើប្រាក់ អញ្ចឹងយើងអាច
យើងអាចដើរមករកទូអេធីអឹមដើម្បីដកប្រាក់ទាំងអស់នោះ។ អញ្ចឹងការប្រើប្រាស់កាតអេធីអឹម
គឺងាយស្រួល គឺងាយស្រួល និង គឺងាយស្រួល និងមិនចាំបាច់ខ្វាយខ្វល់ថា នៅពេលដែលយើង
នៅពេលដែលមានចោរលួច ឬក៏នៅពេលដែលមានចោរឆក់កាបូបរបស់យើង
គឺយើងបាត់លុយនោះទេ អញ្ចឹងប្រសិនបើ មានចោរលួច ឬក៏នៅពេលដែលយើងបាត់កាបូបលុយ
ឬក៏បាត់កាត ឬក៏បាត់កាតអេធីអឹមនោះ យើងគ្រាន់តែទៅធនាគារប្រាប់បុគ្គលិកនៅធនាគារ
ដូច្នេះពួកគាត់នឹងប្តូរកាត ឬក៏ធ្វើកាតឲ្យយើងថ្មី អញ្ចឹងយើងមិនចាំបាច់ព្រួយបារម្ភអ្វីទាំងអស់។

រូបភាពទី ១៥ ក្រោយពេលដែលគាត់បានដកលុយចេញពីម៉ាស៊ីនចំនួន ចំនួនលុយ ១៥០០ ដុល្លារ
គាត់ក៏បានដាក់លុយនោះចូលទៅក្នុងកាបូបលុយរបស់គាត់ ដែលកាបូបលុយរបស់គាត់
គាត់ដាក់នៅក្នុងកាបូបស្ពាយចំហៀង ពណ៌ស របស់គាត់ ដែលស្ពាយនៅខាងលើស្មា
ឬក៏នៅចំហៀងដៃខាងស្តាំរបស់គាត់។ អញ្ចឹងគាត់ដកកាបូបលុយនោះចេញពីកាបូបពណ៌ស
បន្ទាប់មកគាត់ក៏បានដាក់លុយចំនួន ១៥០០ ដុល្លារនោះចូលទៅក្នុងកាបូបដោយប្រុងប្រយ័ត្ន។
បន្ទាប់មកទៀត បន្ទាប់មកទៀតរូបភាពទី ១៦ រូបភាពទី ១១ រូបភាពទី ១៦
ក្រោយពេលដែលស្ត្រីម្នាក់នោះគាត់បាន គាត់បានដកលុយចេញពីម៉ាស៊ីនចំនួន ១៥០០ ដុល្លារ
និងបានដាក់ចូលទៅក្នុងកាបូបលុយរបស់គាត់ បន្ទាប់មកគាត់ក៏បិទកាបូបលុយរបស់គាត់

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

និងដាក់កាបូបលុយរបស់គាត់ចូលទៅក្នុងកាបូបស្ពាយចំហៀងរបស់គាត់វិញ
និងដៃខាងស្តាំរបស់គាត់កាន់កាបូប កាន់កាបូបស្ពាយចំហៀងរបស់គាត់យ៉ាងជាប់
ដោយសារតែគាត់ខ្លាចនៅពេលដែលគាត់ដើរលឿន កាបូបនោះអាចរអិលធ្លាក់ចុះមកខាងក្រោម។
អញ្ចឹងគាត់ត្រូវកាន់កាបូបនោះ បើទោះបីជាគាត់ស្ពាយនៅលើស្មាខាងស្តាំរបស់គាត់ក៏ដោយ។
អញ្ចឹងគាត់បានដើរ អញ្ចឹងគាត់ក្រោយពេលដែលដកលុយ គាត់ក៏បានដើរត្រលប់ទៅវិញ
ប្រហែលជាគាត់ត្រលប់ទៅផ្ទះរបស់គាត់ ឬក៏ប្រហែលជាគាត់ ឬក៏គាត់ទៅផ្សារដើម្បីទិញអីវ៉ាន់។
បន្ទាប់ ក្រោយពេលដែលគាត់ ក្រោយពេលដែលគាត់ចេញពីទូ
ក្រោយពេលដែលគាត់ដើរចេញពីទូអេធីអឹមនោះ យើងឃើញមានស្ត្រីម្នាក់ទៀត ក៏បានដើរចូល
ដើម្បីដកលុយចេញពីទូ ដើម្បីដកលុយពីទូអេធីអឹមនោះ។ ដោយយើងឃើញស្ត្រីម្នាក់នោះ
គឺគាត់ពាក់អាវស យឺតដៃខ្លី ជាមួយនឹងខោជើងវែងពណ៌ខ្មៅ គាត់មានចងសក់
គាត់ចងសក់នៅខាងក្រោយផងដែរ។ អញ្ចឹង អញ្ចឹងយើងឃើញគាត់កំពុងតែដើរចូល
ដើម្បីស៊កកាតចូលទៅក្នុងម៉ាស៊ីន ឬក៏ទូអេធីអឹម ដើម្បីអាចដកលុយយកមកប្រើប្រាស់បាន។
អញ្ចឹងការប្រើប្រាស់អេធីអឹម គឺពិតជាងាយស្រួល និងទូអេធីអឹម គឺយើងអាចប្រើប្រាស់ ២៤ ម៉ោង
គ្រប់ពេលដែលយើងត្រូវការលុយ យើងគ្រាន់តែ យើងគ្រាន់តែ យើងគ្រាន់តែ
យើងគ្រាន់តែស៊កកាតអេធីអឹមចូលទៅក្នុងម៉ាស៊ីននោះ យើងអាចដកលុយបានយ៉ាងងាយស្រួល។
អញ្ចឹង អញ្ចឹងភាគច្រើន មនុស្សគាត់ចូល ភាគច្រើនមនុស្សគាត់ចូលចិត្តប្រើអេធីអឹម
ជាងការដាក់ប្រាក់ ជាងការដាក់ប្រាក់ជាច្រើននៅក្នុងកាបូបរបស់គាត់។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.